ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ

## ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំមាន ពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាព និងរបាយការណ៍សម្រាប់ក្រុមការងារបច្ចេកទេសបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។

តាមរយៈនៃកិច្ចប្រជុំសមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងបានការឯកភាពលើផែនការសកម្មភាពរួមសម្រាប់ឆ្នាំ២០១៧ និងការរៀបចំរបាយការណ៍ឆ្នាំ២០១៦។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ: ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧

ទីកន្លែង : នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍,MHC, MHSS,SIT,RHAC,FHI360, and KHEMARA.

### ៣-វិធីសាស្ត្រ ពិភាក្សារួម

### ៤-លទ្ធផល

នៅថ្ងៃព្រហស្បត៍ ទី២៦ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារ លេខាធិការដ្ឋានបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទដែលមានសមាជិកចូលរួមប្រមាណ០៨នាក់ ក្រោមការសម្របសម្រួលកិច្ចប្រជុំដោយលោកវេជ្ជ.អ៊ឹង សុវណ្ណៈ។

ជាកិច្ចចាប់ផ្តើម លោកប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការ ដែលបានចូលរួមប្រជុំនាពេលនេះព្រមទាំង ពិនិត្យ និងពិភាក្សាលំអិតលើរបៀបវារៈនីមួយៗដែលបានគ្រោងទុក ដោយសម្រេចលទ្ធផលដូចខាងក្រោម៖

១.ការរៀបចំផែនការសកម្មភាពឆ្នាំ២០១៧ សម្រាប់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទបានសម្រេចបញ្ចូលរួមគ្នារវាងផែនការសកម្មភាពរបស់អង្គការដៃគូ និងបន្ថែមនូវសំណូមពរពីកិច្ចប្រជុំលើកមុន ជាលទ្ធផលបានឯកភាពការគ្នាលើផែនការសកម្មភាពឆ្នាំ២០១៧ ។

២.សម្រេចរៀបចំរបាយការណ៍ប្រចាំឆ្នាំ២០១៦ ដោយសមាជិកក្នុងកិច្ចប្រជុំឯកភាពគ្នាផ្តល់ឲ្យខាងអង្គការខាណា និងបណ្តាញចតុមុខជាអ្នករៀបចំ។

**៥-ការងារដែលត្រូវធ្វើបន្ត**

១.ក្រុមការងារលេខាធិការដ្ឋាននឹងរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧។

៣.រៀបចំរបាយការណ៍របស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទឆ្នាំ២០១៦។

ភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧

បានឃើញ និងពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋាន

អ្នកធ្វើរបាយការណ៍